# ហើយចិត្តនៃកូនចៅនឹងត្រូវបានបង្វែរមកវក

*ដោយ អែលឌើរ ដេវីឌ អេ បែដណា*
*នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់*

ពេលយើងសិក្សា រៀន និងរស់តាមដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ ជាញឹកញាប់អ្វីដែលកើតឡើងបន្ទាប់នោះគឺមានអត្ថប្រយោជន៍ណាស់ ។ ឧទាហរណ៍សូមធ្វើការពិចារណានូវមេរៀនដែលយើងរៀនអំពីរឿងអាទិភាពខាងវិញ្ញាណក្នុងហេតុការណ៍ដ៏សំខាន់ៗដែលបានកើតឡើងតាមលំដាប់លំដោយ នៅពេលដំណឹងល្អដ៏ពេញលេញរបស់ព្រះអង្គសង្គ្រោះត្រូវបានស្ដារឡើងវិញ នៅក្នុងថ្ងៃចុងក្រោយនេះ ។

នៅក្នុងព្រៃពិសិដ្ឋ លោកយ៉ូសែប ស្ម៊ីធ បានឃើញ និងបានសន្ទនាជាមួយព្រះវរបិតាសួគ៌ និងព្រះយេស៊ូវគ្រីស្ទ ។ នៅក្នុងចំណោមរឿងជាច្រើនទៀតក្នុងនោះលោកយ៉ូសែប បានរៀនអំពីនិស្ស័យពិតប្រាកដនៃក្រុមព្រះ និងវិវរណៈដែលមានជាបន្តបន្ទាប់ ។ នៅក្នុងទស្សននិមិត្តដ៏មានព្រះចេស្ដាដែលបានចាប់ផ្ដើមនូវ « ការកាន់កាប់គ្រួតត្រាក្នុងកាលដែលពេលពេញកំណត់ » ( អេភេសូរ 1:10 ) ហើយនេះគឺជាហេតុការណ៍ដ៏សំខាន់បំផុតនៅក្នុងប្រវត្តិសាស្ត្រនៃពិភពលោក ។

ប្រហែលជាបីឆ្នាំក្រោយមក ជាការឆ្លើយតបនឹងការអធិស្ឋានដ៏ស្មោះត្រង់ នៅរាត្រីថ្ងៃទី 21 ខែ កញ្ញា ឆ្នាំ 1823 នៅលើគ្រែរបស់លោកយ៉ូសែប មានពន្លឺមួយចេះតែភ្លឺឡើងៗ រហូតមានពន្លឺភ្លឺជាង « ពន្លឺថ្ងៃត្រង់ទៅទៀត » ( យ៉ូសែប ស្ម៊ីធ—ប្រវត្តិ 1:30 ) ។ មានតួអង្គមួយបានលេចឡើងនៅក្បែរគ្រែរបស់គាត់ បានហៅយុវជនរូបនោះតាមឈ្មោះ ហើយបានប្រកាសថា « លោកជាទូតដែលបានចាត់មកពីវត្តមាននៃព្រះ...ហើយថាឈ្មោះលោកគឺមរ៉ូណៃ » ( ខទី 33 ) ។ លោកបានបង្រៀនយ៉ូសែប អំពីការចេញមកនូវព្រះគម្ពីរមរមន ។ ហើយបន្ទាប់មក មរ៉ូណៃ បានដកស្រង់ចេញពីព្រះគម្ពីរម៉ាឡាគី នៅក្នុងព្រះគម្ពីរសញ្ញាចាស់ថា ដែលភាសាត្រូវផ្លាស់ប្ដូរបន្តិចដែលបានប្រើនៅក្នុងកំណែរបស់ស្ដេចជេមស៍ ៖ « មើលចុះ យើងនឹងបើកសម្ដែងដល់អ្នករាល់គ្នានូវបព្វជិតភាពដោយដៃនៃអេលីយ៉ា ដែលជាព្យាការី មុនដែលថ្ងៃដ៏ធំ ហើយគួរស្ញែងខ្លាចនៃព្រះអម្ចាស់បានមកដល់... ។

« ហើយលោកនឹងដាក់នៅក្នុងចិត្តនៃកូនចៅនូវសេចក្ដីសន្យាដែលបានធ្វើដល់ពួកឪពុក ហើយចិត្តនៃកូនចៅនឹងបានបង្វែរមកវកពួកឪពុករបស់ពួកគេវិញ ។ បើសិនជាមិនមែនដូច្នោះទេ នោះផែនដីទាំងមូលនឹងត្រូវកំទេចចោលសូន្យឈឹង ក្នុងកាលទ្រង់យាងមក » ( ខទី 1:38, 39 ) ។

ការណែនាំរបស់មរ៉ូណៃទៅដល់ព្យាការីវ័យក្មេង នៅទីបំផុតបានបន្ថែមនូវប្រធានបទ ពីរសំខាន់ៗ ៖ ( 1 ) ព្រះគម្ពីរមរមន និង ( 2 ) ពាក្យសំដីរបស់ម៉ាឡាគី ទស្សទាយនូវតួនាទីរបស់អេលីយ៉ា នៅក្នុងការស្ដារឡើងវិញ « ទាំងអស់ដែលព្រះមានបន្ទូលប្រាប់ពីគ្រានោះ ដោយសារមាត់នៃពួកហោរាបរិសុទ្ធរបស់ទ្រង់តាំងពីបុរាណមក » ( កិច្ចការ 3:21 ) ។ ដូច្នេះហើយ ហេតុការណ៍ដែលកើតឡើងដំបូងនៃការស្ដារឡើងវិញបានបើកសម្ដែងនូវការយល់ដឹងដ៏ត្រឹមត្រូវពីក្រុមព្រះ ដែលបានបញ្ជាក់អំពីសារៈសំខាន់នៃព្រះគម្ពីរមរមន និងការចូលរួមចំណែកនៅក្នុងកិច្ចការនៃសេចក្ដីសង្គ្រោះ និងការលើកដំកើងទាំងសម្រាប់ជនដែលរស់នៅ និងជនដែលបានទទួលមរណភាពទៅ ។ ហេតុដែលកើតឡើងដោយការបំផុសគំនិតនេះគឺជាការបង្រៀនអំពីកិច្ចការខាងវិញ្ញាណដែលមានអាទិភាពខ្ពស់បំផុតចំពោះព្រះ ។

សារលិខិតរបស់ខ្ញុំផ្ដោតសំខាន់ទៅលើការបម្រើ និងវិញ្ញាណនៃអេលីយ៉ា ដែលបានទស្សទាយដោយមរ៉ូណៃ នៅក្នុងការណែនាំដំបូងរបស់លោកទៅកាន់យ៉ូសែប ស្ម៊ីធ ។ ខ្ញុំសូមអធិស្ឋានដោយស្មោះត្រង់ដើម្បីទទួលបាននូវជំនួយនៃព្រះវិញ្ញាណបរិសុទ្ធ ។

## ការបម្រើនៃអេលីយ៉ា

អេលីយ៉ាគឺជាព្យាការីនៅក្នុងគម្ពីរសញ្ញាចាស់ ដែលតាមរយៈលោក អព្ភូតហេតុដ៏មហិមាបានកើតឡើង ។ លោកបានចងស្ថានសួគ៌ ហើយគ្មានភ្លៀងធ្លាក់អស់ 3 ឆ្នាំកន្លះ នៅក្នុងសម័យអ៊ីស្រាអែលកាលពីបុរាណ ។ លោកបានចម្រើនឡើងអាហារ និងប្រេងរបស់ស្ត្រីមេម៉ាយ ។ លោកបានប្រោសក្មេងប្រុសម្នាក់ឲ្យរួចពីស្លាប់ ហើយលោកបានអំពាវនាវឲ្យភ្លើងធ្លាក់ពីស្ថានសួគ៌ដើម្បីធ្វើជាការប្រឆាំងនឹងពួកហោរានៃព្រះបាល ( សូមមើល

ពង្សាវតារក្សត្រទី 1 17–18 ) ។ នៅចុងបញ្ចប់នៃការបម្រើរបស់អេលីយ៉ាក្នុងជីវិតរមែងស្លាប់ លោក « ក៏ឡើងទៅឯស្ថានសួគ៌ដោយខ្យល់កួច » ( ពង្សវតារក្សទី 2 2:11 ) ហើយក៏ត្រូវបានយកទៅស្ថានសួគ៌ ។« យើងរៀនចេញពីវិវរណៈនៅសម័យចុងក្រោយថា អេលីយ៉ា កាន់នូវអំណាចផ្សារភ្ជាប់នៃបព្វជិតភាពមិលគីស្សាដែក ហើយជាព្យាការីចុងក្រោយដើម្បីធ្វើកិច្ចការនោះ ពីមុនដល់ពេលនៃការយាងមករបស់យេស៊ូវ គ្រីស្ទ » ( សេចក្ដីណែនាំដល់បទគម្ពីរទាំងឡាយ « អេលីយ៉ា » ) ។

ព្យាការីយ៉ូសែប ស្ម៊ីធ បានពន្យល់ថា « វិញ្ញាណ អំណាច និងការហៅរបស់អេលីយ៉ា គឺដើម្បីឲ្យអ្នកមានអំណាចដើម្បីកាន់កូនសោ ... ដ៏ពេញលេញនៃបព្វជិតភាពមិលគីស្សាដែក ...និងដើម្បី ...ទទួល ... ពិធីបរិសុទ្ធទាំងអស់ដែលជាកម្មសិទ្ធរបស់នគរនៃព្រះ » (*Teachings of Presidents of the Church: Joseph Smith* [ ឆ្នាំ 2007 ] ទំព័រ 311 បន្ថែមអក្សរទ្រេត ) ។ សិទ្ធិអំណាចនៃការផ្សារភ្ជាប់ដ៏ពិសិដ្ឋនេះគឺមានសារៈសំខាន់ចំពោះពិធីបព្វជិតភាពដ៏បរិសុទ្ធទាំងឡាយ ដើម្បីមានសុពលភាព និងចងភ្ជាប់ទាំងនៅលើផែនដី និងស្ថានសួគ៌ ។

អេលីយ៉ា បានប្រាកដខ្លួនចំពោះម៉ូសេនៅឯភ្នំប្រែរូប ( សូមមើល ម៉ាថាយ 17:3 ) ហើយបានប្រគល់សិទ្ធិអំណាចនេះទៅលើ ពេត្រុស យ៉ាកុប និងយ៉ូ-ហាន ។ អេលីយ៉ា បានប្រាកដខ្លួនឡើងចំពោះម៉ូសេជាថ្មីម្តងទៀត និងអ្នកដទៃនៅថ្ងៃទី 3 ខែ មេសា ឆ្នាំ 1836 ក្នុងព្រះវិហារបរិសុទ្ធខឺតឡង់ ហើយបានប្រគល់កូនសោដូចគ្នានោះទៅឲ្យព្យាការីយ៉ូសែប ស្ម៊ីធ និង
អូលីវើរ ខៅឌើរី ។

ព្រះគម្ពីរបានកត់ត្រាថា អេលីយ៉ាជាព្យាការីបានឈរពីមុនលោកយ៉ូសែប និងអូលីវើរ ហើយបាននិយាយថា ៖ « មើលចុះ ពេលវេលាបានមកដល់ពេញលេញហើយ ដែលបានពោលដោយមាត់នៃលោកម៉ាឡាគី — ដោយធ្វើទីបន្ទាល់ថា លោក [ អេលីយ៉ា ] នឹងត្រូវបានចាត់ឲ្យមកមុនថ្ងៃដ៏ធំ ហើយគួរស្ញែងខ្លាចនៃព្រះអម្ចាស់នឹងមកដល់ — « ដើម្បីបង្វែរចិត្តពួកឪពុកមកឯកូន និងចិត្តកូនមកឯឪពុក ក្រែងផែនដីទាំងមូលនឹងត្រូវវាយដោយសេចក្តីបណ្តាសា — ដូច្នេះហើយ កូនសោទាំងឡាយនៃគ្រាកាន់កាប់ត្រួតត្រានេះ ត្រូវបានប្រគល់ទៅក្នុងដៃរបស់អ្នក ហើយដោយសារការណ៍នេះ ទើបអ្នករាល់គ្នាអាចបានដឹងថាថ្ងៃដ៏ធំនិងគួរស្ញែងខ្លាចនៃព្រះអម្ចាស់ជិតមកដល់ហើយ គឺនៅមាត់ទ្វារ » ( គ. និង ស. 110:14–16 ) ។

ការស្តារឡើងវិញនៃសិទ្ធិអំណាចនៃការផ្សាភ្ជាប់ដោយអេលីយ៉ា នៅក្នុងឆ្នាំ 1836 គឺចាំបាច់ដើម្បីរៀបចំពិភពលោកសម្រាប់ការយាងមកជាលើកទីពីរ និងផ្តួចផ្តើមឲ្យមានការចាប់អារម្មណ៍កាន់តែច្រើនឡើងទូទាំងពិភពលោកនៅក្នុងការស្រាវជ្រាវពង្សប្រវត្តិក្រុមគ្រួសារ ។

**វិញ្ញាណ និងកិច្ចការរបស់អេលីយ៉ា**

ព្យាការីយ៉ូសែប ស្ម៊ីធ បានប្រកាសថា ៖ « ការទទួលខុសត្រូវដ៏ធំបំផុតនៅក្នុងពិភពលោកនេះដែលព្រះបានដាក់មកលើយើង គឺដើម្បីស្វែងរកពីជីដូនជីតារបស់យើងដែលបានទទួលមរណភាពទៅ ... ។ ពីព្រោះវាមានសារៈសំខាន់ដែលថា អំណាចនៃការផ្សាភ្ជាប់គួរតែមាននៅក្នុងដៃរបស់យើង ដើម្បីផ្សាភ្ជាប់កូនចៅរបស់យើងនឹងជីដូនជីតារបស់យើងដែលបានទទួលមរណភាព សម្រាប់គ្រាកាន់កាប់ត្រួត្រាដ៏ពេញលេញ — គ្រាកាន់កាប់ត្រួតត្រា ដើម្បីត្រូវនឹងសេចក្តីសន្យាដែលបានធ្វើឡើងដោយព្រះយេស៊ូវគ្រីស្ទ ពីមុនការចាប់ផ្តើមនៃពិភពលោក សម្រាប់ការសង្គ្រោះដល់មនុស្ស ... ។ តាំងពីដើមឡើយ ព្រះបានមានបន្ទូលថា ‹ យើងនឹងចាត់អេលីយ៉ា គឺជាព្យាការីឲ្យមកអ្នករាល់គ្នា › » (*Teachings: Joseph Smith* ទំព័រ 475) ។

លោកយ៉ូសែប បានបន្តពន្យល់ថា « ប៉ុន្តែតើអ្វីទៅជាគោលបំណងនៃ [ ការមកដល់នៃអេលីយ៉ានោះ ] ? ឬតើវាត្រូវបានបំពេញយ៉ាងដូចម្តេចទៅ ? កូនសោគឺត្រូវតែផ្តល់ឲ្យ វិញ្ញាណរបស់អេលីយ៉ាត្រូវតែបញ្ជូនមក ដើម្បីឲ្យដំណឹងល្អត្រូវបានស្ថាបនាឡើង ដើម្បីឲ្យពួកបរិសុទ្ធរបស់ព្រះត្រូវបានប្រមូលផ្តុំ ដើម្បីឲ្យស៊ីយ៉ូនត្រូវសាងសង់ឡើង និងដើម្បីឲ្យពួកបរិសុទ្ធឡើងមកធ្វើជាអ្នកសង្គ្រោះនៅលើភ្នំស៊ីយ៉ូន [ សូមមើល អូបាឌា 1:21 ] ។

« ប៉ុន្តែ តើពួកគេនឹងក្លាយជាអ្នកសង្គ្រោះនៅលើភ្នំស៊ីយ៉ូនយ៉ាងដូចម្តេចទៅ ? តាមរយៈការស្ថាបនាព្រះវិហារបរិសុទ្ធរបស់ពួកគេ ... និងទៅទទួល និងការទទួលយកនូវពិធីបរិសុទ្ធទាំងអស់ ... ជំនួសឲ្យបុព្វបុរសរបស់ពួកគេដែលបានទទួលមរណភាពទៅ ... ហើយហេតុដូច្នោះហើយ គឺជាច្រវាក់ដែលចងចិត្តរបស់ឪពុកមកឯកូន ហើយឯកូនទៅរកឪពុក ដែលបំពេញនូវបេសកកម្មរបស់អេលីយ៉ា » (*Teachings: Joseph Smith* ទំព័រ 472–73 ) ។

អែលឌើរ រ័សុល អិម ណិលសុន បានបង្រៀនថាវិញ្ញាណរបស់អេលីយ៉ាគឺជា « ការបង្ហាញពីព្រះវិញ្ញាណបរិសុទ្ធថ្លែងជាសាក្សីពីនិស្ស័យដ៏ទេវភាពនៃក្រុមគ្រួសារ » ( « A New Harvest Time » *Ensign* ខែ ឧសភា ឆ្នាំ 1998 ទំព័រ 34 ) ។ ឥទ្ធិពលនៃការបង្រៀននេះពីព្រះវិញ្ញាណបរិសុទ្ធទាញឲ្យមនុស្សជាច្រើនពិសោធន៍ឲ្យឃើញ ចងក្រង និងស្រឡាញ់បុព្វបុរស និងសមាជិកគ្រួសាររបស់ពួកគេ — ទាំងអតីតកាល និងបច្ចុប្បន្នកាល ។

វិញ្ញាណរបស់អេលីយ៉ា មានឥទ្ធិពលលើមនុស្សទាំងនៅខាងក្រៅ និងខាងក្នុងសាសនាចក្រ ។ ទោះជាយ៉ាងណាក្តី ក្នុងនាមជាសមាជិកនៃសាសនាចក្រដែលបានស្តារឡើងវិញរបស់ព្រះគ្រីស្ទ យើងទទួលខុសត្រូវលើសេចក្តីសញ្ញាក្នុងការស្វែងរកបុព្វបុរសរបស់យើង ហើយធ្វើពិធីបរិសុទ្ធនៃការសង្គ្រោះនៃដំណឹងល្អដល់ពួកលោក ។ « ដើម្បីមិនឲ្យអ្នកទាំងនោះបានគ្រប់លក្ខណ៍ក្រៅពីយើងឡើយ » ( ហេព្រើរ 11:40 សូមមើល *Teachings: Joseph Smith* ទំព័រ 475 ) ។ និង « រីឯយើងក៏ពុំអាចបានល្អឥតខ្ចោះក្រៅពីមនុស្សស្លាប់របស់យើងដែរ » ( គ. និង ស. 128:15 ) ។

ដោយសារតែមូលហេតុទាំងនេះហើយ ដែលយើងធ្វើការស្រាវជ្រាវពង្សប្រវត្តិ សាងសង់ព្រះវិហារបរិសុទ្ធ និងធ្វើពិធីបរិសុទ្ធជំនួសជាច្រើនទៀត ។ ដោយសារតែមូលហេតុទាំងនេះហើយ ទើបអេលីយ៉ា ត្រូវបានបញ្ជូនដើម្បីស្តារឡើងវិញនូវសិទ្ធិអំណាចដើម្បីផ្សារភ្ជាប់ ដែលចងភ្ជាប់នៅលើផែនដី និងនៅលើស្ថានសួគ៌ ។ យើងគឺជាភ្នាក់ងារនៃព្រះអម្ចាស់នៅក្នុងកិច្ចការនៃសេចក្តីសង្គ្រោះ និងការលើកដំកើងដែលនឹងការពារ « ផែនដីទាំងមូល [ ពីការ ] វាយដោយសេចក្តីបណ្តាសា » ( គ. និង ស. 110:15 ) នៅពេលទ្រង់ត្រឡប់មកម្តងទៀត ។ នេះគឺជាករណីយកិច្ចរបស់យើង និងជាពរជ័យដ៏មហិមា ។

## ការអញ្ជើញដល់ជំនាន់ដែលកំពុងពេញវ័យ

ឥឡូវនេះខ្ញុំសូមនិយាយផ្តោតទៅលើយុវនារី និងយុវជន ព្រមទាំងកុមារាកុមារីទាំងឡាយនៃជំនាន់ដែលកំពុងពេញវ័យ នៅពេលខ្ញុំសង្កត់ធ្ងន់ទៅលើសារៈសំខាន់នៃវិញ្ញាណរបស់អេលីយ៉ា នៅក្នុងជីវិតរបស់អ្នកនៅថ្ងៃនេះ ។ សារលិខិតរបស់ខ្ញុំគឺក្នុងគោលបំណងផ្តល់ដល់សាសនាចក្រទាំងមូល — ប៉ុន្តែសម្រាប់អ្នកជាពិសេស ។

ក្នុងចំណោមពួកអ្នក មានអ្នកខ្លះអាចគិតថាកិច្ចការពង្សប្រវត្តិគឺត្រូវធ្វើឡើងជាចម្បងដោយមនុស្សវ័យចំណាស់ ។ ប៉ុន្តែ ខ្ញុំពុំដែលបានឮថាមានបទគម្ពីរណាមួយដែលពិពណ៌នាពីព្រំដែនកំណត់នៃអាយុ ឬគោលការណ៍ណែនាំដែលបានប្រកាសដោយពួកអ្នកដឹកនាំសាសនាចក្រដាក់កំហិតនូវការបម្រើដ៏សំខាន់នេះទៅលើមនុស្សវ័យចំណាស់ឡើយ ។ អ្នកគឺជាបុត្រាបុត្រីនៃព្រះ ជាកូនចៅនៃសេចក្តីសញ្ញា និងជាអ្នកស្ថាបនាព្រះនគរ ។ អ្នកពុំចាំបាច់ត្រូវការរង់ចាំដល់អ្នកមានអាយុដែលបានកំណត់ ដើម្បីបំពេញការទទួលខុសត្រូវដើម្បីជួយក្នុងកិច្ចការនៃសេចក្តីសង្គ្រោះសម្រាប់ក្រុមគ្រួសារមនុស្សឡើយ ។

ព្រះអម្ចាស់បានធ្វើឲ្យមានធនធានដ៏អស្ចារ្យជាច្រើននៅក្នុងសម័យរបស់យើង ដើម្បីធ្វើឲ្យអ្នកទទួលដំណឹង និងស្រឡាញ់កិច្ចការនេះដែលត្រូវបានលើកទឹកចិត្តដោយវិញ្ញាណរបស់អេលីយ៉ា ។ ជាឧទាហរណ៍ កម្មវិធីFamilySearch គឺជាការប្រមូលផ្តុំកំណត់ហេតុ ធនធាន និងការបម្រើទាំងឡាយដែលមានលក្ខណៈងាយស្រួលនៅក្នុងការចូលទៅបានតាមរយៈកុំព្យូទ័រផ្ទាល់ខ្លួន និងតាមរយៈឧបករណ៍ដែលកាន់ក្នុងដៃជាច្រើន ដែលបានរចនាឡើងជាការជួយដល់មនុស្សរកឃើញ និងប្រមូលឯកសារពីពង្សប្រវត្តិរបស់ពួកគេ ។ ធនធានទាំងនេះក៏មានក្នុងមជ្ឈមណ្ឌលពង្សប្រវត្តិដែលមានទីតាំងនៅតាមអគារនៃសាសនាចក្រជាច្រើន នៅទូទាំងពិភពលោក ។

ពុំមែនជាការចៃដន្យទេ ដែលកម្មវិធី FamilySearch និងឧបករណ៍ផ្សេងៗទៀតបានកើតមានឡើងនៅក្នុងពេលនេះ នៅពេលមនុស្សវ័យក្មេងរកឃើញនូវព័ត៌មាន និងបច្ចេកវិជ្ជាទំនាក់ទំនងដ៏សន្ធឹកសន្ធាប់នោះ ។ ម្រាមដៃរបស់អ្នកត្រូវបានហ្វឹកហ្វាត់ដើម្បីវាយអត្ថបទ និងសម្លេងផ្ញើសារដើម្បីពន្លឿន និងធ្វើឲ្យកិច្ចការរបស់ព្រះអម្ចាស់កាន់តែមានការឆាប់រហ័ស — នោះមិនត្រឹមតែធ្វើឲ្យទំនាក់ទំនងរបស់អ្នកជាមួយមិត្តភក្តិមានការឆាប់រហ័សនោះទេ ។ ជំនាញ និងភស្តុតាងដ៏មានទេពកោសល្យនៅក្នុងចំណោមមនុស្សវ័យក្មេងនាសព្វថ្ងៃនេះគឺជាការរៀបចំដើម្បីជាការបរិច្ចាគដល់កិច្ចការនៃសេចក្តីសង្គ្រោះ ។

ខ្ញុំសូមអញ្ជើញមនុស្សវ័យក្មេងនៃសាសនាចក្រ ដើម្បីដឹង និងទទួលបទពិសោធន៍នូវវិញ្ញាណរបស់អេលីយ៉ា ។ ខ្ញុំសូមលើកទឹកចិត្តអ្នកឲ្យសិក្សា ស្វែងរកពីបុព្វបុរសរបស់អ្នក និងរៀបចំខ្លួនរបស់អ្នកក្នុងការធ្វើពិធីបុណ្យជ្រមុជទឹកជំនួសនៅក្នុងដំណាក់នៃព្រះអម្ចាស់សម្រាប់សាច់សណ្តានរបស់អ្នក ដែលបានទទួលមរណភាព ( សូមមើល គ. និង ស. 124:28–36 ) ។ ហើយខ្ញុំសូមជំរុញអ្នកឲ្យជួយដល់មនុស្សស្គាល់ពីពង្សប្រវត្តិរបស់ពួកគេ ។

នៅពេលអ្នកធ្វើតាមដោយសេចក្តីជំនឿចំពោះការអញ្ជើញនេះ នោះចិត្តរបស់អ្នកនឹងបង្វែរទៅរកឪពុក ។ សេចក្តីសន្យាដែលបានធ្វើឡើងចំពោះ អ័ប្រាហាំ អ៊ីសាក និងយ៉ាកុប នឹងត្រូវបានចាស់ឫសគល់នៅក្នុងដួងចិត្តរបស់អ្នក ។ ពរជ័យលោកអយ្យកោរបស់អ្នក ដែលវាមានប្រាប់នូវពង្សរបស់អ្នក នឹងភ្ជាប់អ្នកទៅនឹងបុព្វបុរសទាំងនេះរបស់អ្នក ហើយនឹងធ្វើឲ្យវាកាន់តែមានអត្ថន័យ ។ សេចក្តីស្រឡាញ់ និងអំណរគុណចំពោះបុព្វបុរសរបស់អ្នកនឹងមានកាន់តែច្រើនឡើង ។ ទីបន្ទាល់របស់អ្នក និងការផ្លាស់ប្រែចិត្តជឿចំពោះព្រះអង្គសង្គ្រោះនឹងកាន់តែស៊ីជំរៅ និងជាប់ជានិច្ច ។ ហើយខ្ញុំសូមសន្យានឹងអ្នកថា អ្នកនឹងត្រូវបានការការពារប្រឆាំងនឹងឥទ្ធិពលដ៏ខ្លាំងក្លារបស់ពួកមាសត្រូវ ។ពេលអ្នកចូលរួម ហើយស្រឡាញ់កិច្ចការដ៏បរិសុទ្ធនេះ នោះអ្នកនឹងមានសុវត្ថិភាពក្នុងយុវវ័យរបស់អ្នក ហើយនៅពេញមួយជីវិតរបស់អ្នក ។

ឪពុកម្តាយ និងអ្នកដឹកនាំទាំងឡាយ សូមជួយដល់កូនចៅរបស់អ្នក និងយុវវ័យរបស់អ្នកឲ្យរៀន និងពិសោធន៍នូវវិញ្ញាណរបស់អេលីយ៉ា ។ ប៉ុន្តែសូមកុំផ្តល់ឲ្យកម្មវិធីច្រើនហួសហេតុដល់មនុស្សវ័យក្មេងទាំងនេះ ឬផ្តល់ឲ្យនូវព័តមានលំអិត ឬការបំពាក់បំប៉នច្រើនពេក ។ ខ្ញុំសូមអញ្ជើញមនុស្សវ័យក្មេងឲ្យរុករក និងពិសោធន៍ ហើយរៀនសម្រាប់ខ្លួនគេផ្ទាល់ ( សូមមើល យ៉ូសែប ស៊្មីធ — ប្រវត្តិ 1:20 ) ។ មនុស្សវ័យក្មេងគ្រប់រូបអាចធ្វើអ្វីដែលខ្ញុំកំពុងតែស្នើ

សុំនេះ ដោយប្រើកម្មវិធីដែលមានក្នុង lds.org/familyhistoryyouth។ កូរ៉ុមបព្វជិតភាពអើរ៉ុន និងគណៈប្រធានយុវនារីអាចដើរតួយ៉ាងសំខាន់នៅក្នុងការជួយដល់យុវវ័យទាំងអស់ឲ្យចេះពីធនធានគ្រឹះទាំងនេះ ។ ចំនួនមនុស្សវ័យក្មេងដែលត្រូវការក្លាយជាអ្នករៀនសូត្រ ដែលជាអ្នកធ្វើ ហើយទទួលពន្លឺ និងចំណេះដឹងបន្ថែមតាមរយៈអំណាចនៃព្រះវិញ្ញាណបរិសុទ្ធកាន់តែមានចំនួនកើនឡើង — ហើយពុំកម្រមានសិស្សដែលខ្ជិលច្រអូសក្លាយជាអ្នកដែលនឹងធ្វើនូវកិច្ចការទាំងនេះឡើយ ( សូមមើលនីហ្វៃទី 2 2:26 ) ។

ឪពុកម្ដាយ និងពួកអ្នកដឹកនាំទាំងឡាយ អ្នកនឹងងឿឆ្ងល់ពីរបៀបដែលកូនចៅ និងយុវវ័យនៃសាសនាចក្ររបស់អ្នកក្លាយជាមនុស្សមានទេពកោសល្យដ៏ច្រើនពីឧបករណ៍ទាំងនេះ ។ ជាការពិតណាស់ អ្នកនឹងរៀននូវមេរៀនដ៏មានតម្លៃមកពីមនុស្សវ័យក្មេងទាំងនេះអំពីការប្រើប្រាស់នូវធនធានទាំងនេះប្រកបដោយប្រសិទ្ធភាព ។ ពួកយុវវ័យអាចជួយដល់មនុស្សមានវ័យចំណាស់ជាច្រើនដែលពុំចេះនូវបច្ចេកវិជ្ជាមានថ្មីៗ ឬមិនសូវចេះនូវកម្មវិធី FamilySearch ។ ហើយអ្នកនឹងរាប់នូវពរជ័យជាច្រើនរបស់អ្នក នៅពេលមនុស្សវ័យក្មេងពលិកម្មពេលវេលាជាច្រើនថែមទៀតដល់កិច្ចការពង្សប្រវត្តិ និងការបម្រើក្នុងព្រះវិហារបរិសុទ្ធ ហើយចំណាយពេលតិចតួចដើម្បីលេងល្បែងវីដេអូ ស្រាវជ្រាវលើអ៊ិនធើរណែត និងលេង Facebookនោះ ។

ត្រូយ ជេកសាន់ ដែរិន ហូប និងអែនត្រូ អាឡេន គឺជាអ្នកកាន់បព្វជិតភាពអើរ៉ុន ជាអ្នកដែលត្រូវបានហៅដោយប៊ីស្សពដ៏បំផុសគំនិតម្នាក់ ឲ្យបង្កើតក្រុមមួយបង្រៀនថ្នាក់ពង្សប្រវត្តិក្នុងវួដរបស់ពួកគេ ។ ពួកយុវជនទាំងនេះគឺជាអ្នកតំណាងឲ្យអ្នករាល់គ្នានៅក្នុងការស្រេកឃ្លានក្នុងការរៀនសូត្ររបស់ពួកគេ និងមានបំណងប្រាថ្នាក្នុងការបម្រើ ។

ត្រូយ និយាយថា ៖ « ខ្ញុំធ្លាប់គ្រាន់តែមកព្រះវិហារ ហើយអង្គុយនៅមួយកន្លែង ប៉ុន្តែឥឡូវនេះខ្ញុំដឹងថា ខ្ញុំត្រូវទៅផ្ទះ ហើយធ្វើអ្វីផ្សេងទៀត ។ យើងទាំងអស់គ្នាអាចធ្វើកិច្ចការពង្សប្រវត្តិបាន ។

ដែរិន បានរាយការណ៍ថា នៅពេលដែលគាត់រៀនបន្ថែមទៀតអំពីកិច្ចការពង្សប្រវត្តិនោះគាត់បានដឹងថា « វាមិនមែនគ្រាន់តែជាឈ្មោះនោះទេ វាគឺជាមនុស្សពិតៗ ។ ខ្ញុំកាន់តែមានចិត្តរំភើបឡើងៗអំពីការយកឈ្មោះទាំងនោះទៅព្រះវិហារបរិសុទ្ធ » ។

ហើយ អែនត្រូ បានថ្លែងថា « ខ្ញុំបានធ្វើកិច្ចការពង្សប្រវត្តិដោយសេចក្ដីស្រឡាញ់ និងកម្លាំងដែលខ្ញុំមិនបានដឹងថាខ្ញុំអាចប្រមូលបានឡើយ ។ ពេលខ្ញុំចាប់ផ្ដើមរៀបចំជារៀងរាល់សប្ដាហ៍ដើម្បីបង្រៀន ជាញឹកញាប់ខ្ញុំត្រូវបានបំផុសគំនិតដោយព្រះវិញ្ញាណបរិសុទ្ធដើម្បីធ្វើ និងសាកល្បងនូវវិធីសាស្ត្រដែលបានបង្រៀននៅក្នុងមេរៀន ។ ពីមុន កម្មវិធីពង្សប្រវត្តិនេះគឺគួរឲ្យខ្លាចណាស់ ។ ប៉ុន្តែដោយសារមានជំនួយពីព្រះវិញ្ញាណ នោះខ្ញុំអាចបោះជំហានទៅមុខចំពោះការហៅរបស់ខ្ញុំ និងជួយមនុស្សជាច្រើននៅក្នុងវួដរបស់យើង » ។

ប្អូនប្រុសស្រីវ័យក្មេងជាទីស្រឡាញ់របស់ខ្ញុំអើយ កិច្ចការពង្សប្រវត្តិគឺពុំមែនជាកម្មវិធីមួយគួរឲ្យចាប់អារម្មណ៍ ឬជាសកម្មភាពដែលត្រូវបានឧបត្ថម្ភឡើងដោយសាសនាចក្រប៉ុណ្ណោះទេ ផ្ទុយទៅវិញ វាគឺជាផ្នែកមួយដ៏មានសារៈសំខាន់នៅក្នុងសេចក្ដីសង្គ្រោះ និងការលើកដំកើង ។ អ្នកត្រូវបានរៀបចំទុកសម្រាប់សម័យនេះ និងដើម្បីស្ថាបនានគរព្រះ ។ អ្នកនៅលើផែនដីនាពេលឥឡូវនេះ ដើម្បីជួយនៅក្នុងកិច្ចការដ៏រុងរឿងនេះ ។

ខ្ញុំសូមថ្លែងទីបន្ទាល់ថា អេលីយ៉ា បានត្រឡប់មកកាន់ផែនដីវិញ ហើយបានស្ដារឡើងវិញនូវសិទ្ធអំណាចនៃការផ្សាភ្ជាប់ ។ ខ្ញុំសូមថ្លែងជាសាក្សីថា អ្វីដែលបានចងនៅលើផែនដី និងបានចងនៅលើស្ថានសួគ៌ ។ ហើយខ្ញុំដឹងថាពួកយុវវ័យនៅក្នុងជំនាន់ដែលកំពុងពេញវ័យមានតួនាទីដ៏សំខាន់ដើម្បីធ្វើនៅក្នុងកិច្ចខិតខំដ៏ខ្លាំងក្លានេះ ។ ខ្ញុំក៏សូមថ្លែងទីបន្ទាល់នៅក្នុងព្រះនាមដ៏ពិសិដ្ឋនៃព្រះអម្ចាស់ព្រះយេស៊ូវគ្រីស្ទ អាម៉ែន ។